ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខៈ ០៦ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំក្រុមការងារបញ្ញោបយេនឌ័រ នៅទីស្តីការគណៈរដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

# សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារបញ្ញោបយេនឌ័រ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោមៈ

១. ឯកឧត្តម **សេង លឹមនៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២. លោកជំទាវ **ឆាយ ច័ាន់នឿន** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣. លោកជំទាវ **សុខ វិឡាយ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៤. លោកជំទាវ **ចំរើន ភគិភា** អគ្គលេខាធិការរង គ.ជ.ប.អ អនុប្រធាន

៥. លោកជំទាវ **នាង លីណា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សមាជិក

៦. លោកជំទាវ **ឌុច សុគន្ធ** ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច សមាជិក

៧. លោក **ញ៉ៀម ម៉ារណេត** ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងអភិវឌ្ឍន៍ គ.ជ.ប.អ សមាជិកអចិន្ត្រៃយ៍

៨. លោកស្រី **ចិន ច័ន្ទមុន្នី** អនុប្រធាននាយកដ្ឋានប្រឆាំងអំពើពុករលួយ សមាជិក

៩. លោក **សំ បូណា** អនុប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

១០. លោកស្រី **អ៊ុំ ពុន្នារី** មន្ត្រីនាយកដ្ឋានផែនការ សមាជិក

១១. លោកស្រី **អន នារី** មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.អ សមាជិក

១២. លោកស្រី **កែវ សុជាតិ** ប្រធានផ្នែកធម្មសាស្ត្រ ចរិយាសាស្ត្រ នៃវិទ្យាស្ថានសង្គមសាស្ត្រ មនុស្សសាស្ត្រ នៃរាជបណ្ឌិតសភាកម្ពុជា សមាជិក

**ប្រការ ២.-**

ក្រុមការងារបញ្រ្ជាបយេនឌ័រមានតួនាទី និងភារកិច្ច ដូចខាងក្រោម :

- ពិនិត្យទៅលើកម្មវិធី និងសកម្មភាពតាមផ្នែកនីមួយៗរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងវិភាគរកផលប៉ះពាល់ និងឥទ្ធិពលរបស់សកម្មភាពទាំងអស់នេះទៅលើបុរសស្ត្រី
- ពិនិត្យ និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ លើកម្មវិធី និងគម្រោងថ្មីៗ
- ពិនិត្យលើស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី និងផ្តល់អនុសាសន៍សម្រាប់លើកកម្ពស់ស្ត្រីទៅក្នុងតួនាទីធ្វើសេចក្តីសម្រេច
- ចូលរួមក្នុងការធ្វើផែនការ និងកម្មវិធីនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធានាថា ផែនការ និងកម្មវិធីទាំងនោះមានការឆ្លើយតបនឹងយេនឌ័រ
- បង្កើនចំណេះដឹងស្តីពីទស្សនៈ និងគោលគំនិតយេនឌ័រ និងស្វែងរកការគាំទ្រមតិ ដើម្បីឱ្យកម្មវិធី និង សកម្មភាពនានានៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រីមានការឆ្លើយតបនឹងយេនឌ័រ
- សម្របសម្រួល និងស្វែងរកជំនួយសម្រាប់ការអនុវត្តសកម្មភាពបញ្រ្ជាបយេនឌ័រក្នុងទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៣.-**

ក្រុមការងារយេនឌ័រនេះ ជាផ្នែកមួយនៃទីស្តីការគណៈរដ្ឋមន្ត្រី មានការិយាល័យនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី និងអាចប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញការងារ ។

**ប្រការ ៤.-**

គ្រប់អាជ្ញាធរ អង្គភាព និងនាយកដ្ឋាន ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ០2 ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី

**សុខ អាន**

**កន្លែងទទួល:**

- ក្រសួងកិច្ចការនារី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ